00939759



# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ

ភាគីដាក់ឯកសារ: ក្រុមមេធាវីការពារក្តីលោក នួន ជា

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១៣

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 23-Jul-2013, 13:22
CMS/CFO: Sann Rada

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ សាធារណៈ/Public

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

# សំណើរលើកទី៦ និងចុងក្រោយសុំកោះហៅសាក្សី TCW-223

---

<u>ដាក់ដោយ៖</u>

**ក្រុមមេធាវីការពារក្តី នួន ជា**
Victor KOPPE
Joshua ROSENSWEIG
Forest O'NEILL-GREENBERG
Elizabeth BUDNITZ

<u>**ផ្ញើជូន៖**</u>

**សហចៅក្រមជាប់ចោទ**

**សហព្រះរាជអាជ្ញា**

**លោកស្រី ជា លាង**

**លោក Andrew CAYLEY**

**សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**PICH Ang**
**Elisabeth SIMONNEAU-FORT**

សហមេធាវីអន្តរជាតិសម្រាប់ជនជាប់ចោទ នួន ជា (“មេធាវីការពារក្តី”) តទៅនេះសូមដាក់សំណើលើកទី៦ និងចុងក្រោយ (“សំណើ”) ស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូងកោះហៅសាក្សី TCW-223 ដើម្បីផ្តល់សក្ខីកម្ម:

១. សារណានេះបង្កើតបានជាសំណើលើកទី៦ និងចុងក្រោយរបស់ក្រុមមេធាវីការពារក្តី ស្នើសុំឲ្យសាក្សី TCW-223 ចូលខ្លួនដើម្បីផ្តល់សក្ខីកម្ម ។ គោលបំណងរបស់សំណើនេះ គឺដើម្បីបញ្ចូលប្រវត្តិនីតិវិធី គូសបញ្ជាក់ឡើងវិញមូលហេតុជាច្រើនថា ហេតុអ្វីបានជាសក្ខីកម្មរបស់សាក្សី TCW-223 មានសារសំខាន់ដែលមិនអាចប្រៀបផ្ទឹមបានចំពោះសំណុំរឿងនេះ និងដើម្បីអំពាវនាវជាលើកចុងក្រោយស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូងពិចារណាឡើងវិញ នូវសេចក្តីសម្រេចលើកមុនរបស់ខ្លួន ។

២. សំណើនេះនឹងបម្រើដល់គោលបំណងទីពីរនៃការឆ្លើយតបដោយសង្ខេបទៅនឹងសារណាផ្ទាល់មាត់របស់សហព្រះរាជអាជ្ញានៅថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៣ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយនៅក្នុងសំណុំរឿងដែលធ្វើឡើងដោយ TCW-223។

## I. ប្រវត្តិនីតិវិធី

៣. នៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១១ មេធាវីការពារក្តីបានដាក់បញ្ជីសាក្សីលើកដំបូងរបស់ខ្លួននៅអង្គជំនុំជម្រះសាលាដំបូង[1]។ បញ្ជីនោះរៀបរាប់អំពីអតីតតួនាទីរបស់សាក្សី TCW-223 [redacted] និងជាជម្រើសបានស្វែងរកឲ្យសាក្សីរូបនេះផ្តល់សក្ខីកម្មទាក់ទងនឹងតួនាទីរបស់វៀតណាម និងរចនាសម្ព័ន្ធបញ្ជានៅក្នុងកម្ពុជាប្រជាធិបតេយ្យ និងការជ្រៀតជ្រែកនយោបាយនៅក្នុង អវតក ។ ក្រុមមេធាវីការពារក្តីបានលើកឡើង

---

[1] ឯកសារ **E-9/10.1**, “ដីកាបង្គាប់ឲ្យសម្ភារៈដើម្បីរៀបចំសវនាការ: ឧបសម្ព័ន្ធ ឃ: សេចក្តីសង្ខេបអំពីសាក្សីជាមួយចំណុចនានានៅក្នុងដីកាបញ្ជូនដំណោះស្រាយបញ្ជូនរឿងទៅជំនុំជម្រះ ក្រុមមេធាវីការពារក្តី នួន ជា” ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ ២០១១។

លម្អិតនៅក្នុងសំណើបញ្ជីសាក្សីបច្ចុប្បន្នភាពរបស់ខ្លួនដែលដាក់នៅថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១១[2] ។ សំណើនោះ គឺជាសំណើទីមួយដែលសុំកោះហៅសាក្សី TCW-223។

៤. នៅថ្ងៃទី ៨ និងថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១២ ក្រុមមេធាវីការពារក្តីបានស្នើសុំអង្គជំនុំជម្រះសាលាដំបូងកោះហៅសាក្សីរហូតដល់៤៧នាក់ ទាក់ទងនឹងបញ្ហាបរិបទនៅមុនឆ្នាំ១៩៧៥[3]។ ក្នុងចំណោមសាក្សីដែលបានស្នើឡើង គឺសាក្សី TCW-223 ។ នេះគឺជាសំណើលើកទី២ សុំកោះហៅសាក្សី TCW-223 ។

៥. នៅថ្ងៃទី១៧ ខែសីហាឆ្នាំ ២០១២ ក្រុមមេធាវីការពារក្តីបានស្វែងរកឲ្យចូលខ្លួននៃសាក្សី៧នាក់ រួមទាំងសាក្សី TCW-223 ដើម្បីផ្តល់សក្ខីកម្មទាក់ទងនឹងការជម្លៀសប្រជាជននៅដំណាក់កាលទី១ និងដំណាក់កាលទី២ ។ ក្រុមមេធាវីការពារក្តីលើកអំណះអំណាងថា សាក្សី TCW-223 មានតួនាទីជាន់ខ្ពស់នៅក្នុងឋានុក្រមបក្សកុម្មុយនីស្តកម្ពុជា ជា“[redacted][4]។ ក្រុមមេធាវីការពារក្តីបានផ្តល់អំណះអំណាងបន្ថែមថា ដោយសារវត្តមានរបស់គាត់នៅឯកិច្ចប្រជុំមួយជាមួយ នួន ជា នៅថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៧៥ សាក្សី TCW-223 គឺជាសាក្សីម្នាក់ក្នុងចំណោមសាក្សីតែពីរនាក់ ទៅបីនាក់ប៉ុណ្ណោះ ដែលត្រូវបានគេយល់ថាបានដឹងដោយផ្ទាល់ពីគោលបំណងរបស់ នួន ជា ទាក់ទងនឹងការប្រព្រឹត្តមកលើអតីតទាហាន និងមន្ត្រីរបស់សាធារណៈខ្មែរ ។ ការដឹងនេះត្រូវបានកត់ត្រាដោយលោក Ben Kiernan បន្ទាប់ពីគាត់បានសម្ភាសន៍សាក្សី TCW-223 ដូចខាងក្រោម:

---

[2] ឯកសារ **E-93/4.3** “សម្ភារៈដើម្បីរៀបចំកិច្ចដំណើរការនិតិវិធីជំនុំជម្រះ៖ បញ្ជីសាក្សីបឋម: សេចក្តីសង្ខេបអំពីសាក្សី-ក្រុមមេធាវីការពារក្តី នួន ជា” ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១១ ។

[3] ឯកសារ **E-1/40.1** “ប្រតិចារិតសវនាការ” ថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១២ នៅទំព័រ 3:15-4:7, 32:23-33:9 ។ ឯកសារ **E-155/1** “បញ្ជីសាក្សីបន្ថែមទាក់ទងនឹងបរិបទប្រវត្តិសាស្ត្រ” ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១២។

[4] ឯកសារ **E-189/3/1/7.1.5** “សារណាគាំទ្រសំណើសុំកោះហៅសាក្សីទាក់ទងនឹងការជម្លៀសប្រជាជន ចុះថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១២ (សារណានេះបានដាក់ភ្ជាប់ជាមួយការដាក់ឯកសារបន្តបន្ទាប់នៅអង្គជំនុំជម្រះតុលាការកំពូល)។

សាក្សី TCW-223 ដែលកាលនោះកំពុងរៀនកិច្ចការឃោធាពី សុន សេន ក៏ស្ថិតនៅក្នុងកិច្ចប្រជុំដែរ ។ គាត់រំលឹកអំពីការប្រើប្រាស់ស័ព្ទមួយផ្សេងទៀត: "ពួកគេមិនប្រើពាក្យសម្លាប់ទេ ពួកគេប្រើពាក្យកំចាត់មនុស្សរបស់រដ្ឋាភិបាលចាស់។ កំចាត់ពួកគេមិនត្រូវអនុញ្ញាតឲ្យពួកគេបន្តឋិតនៅក្របខណ្ឌនេះទេ ។ នេះមិនមានន័យកម្ទេចទេ..។ កម្ទេចមានន័យថាសម្លាប់ តែពួកគេប្រើពាក្យទូទៅ គឺកំចាត់ទៅវិញ ។ នួន ជា ប្រើប្រយោគនេះ[5]។

ការពឹងផ្អែកលើសម្រង់នេះ ក្រុមមេធាវីការពារក្ដីលើកអំណះអំណាងភស្តុតាងរបស់សាក្សី TCW-223 គឺពាក់ព័ន្ធយ៉ាងច្បាស់ និងជាភស្តុតាងដោះបន្ទុក ហើយដូច្នេះមេធាវីការពារក្ដីស្វែងរកឲ្យគាត់ផ្ដល់សក្ខីកម្មដោយផ្ទាល់មាត់នៅចំពោះមុខអង្គជំនុំជម្រះនេះ។ នេះគឺជាសំណើលើកទី៣ ស្នើសុំកោះហៅសាក្សី TCW-223 ។

៦. នៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣ ក្រុមមេធាវីការពារក្ដីបានស្វែងរកឲ្យចូលខ្លួននៃសាក្សី TCW-223 ជាសាក្សីតែមួយគត់ពាក់ព័ន្ធនឹងអត្តចារិតរបស់ នួន ជា[6] ។ សំណើនោះបានរៀបរាប់ទំនាក់ទំនងដែលមានរយៈពេល៦០ឆ្នាំរវាង នួន ជា និងសាក្សី TCW-223 រួមទាំងរយៈពេលពីរទសវត្សរ៍ដែលពួកគេទាំងពីរធ្វើការងារជាមួយគ្នាយ៉ាងជិតស្និទ្ធ ដើម្បីធ្វើឲ្យសម្រេចនូវគោលបំណងបដិវត្តន៍សង្គមនិយមនៅកម្ពុជា:

ទំនាក់ទំនងរបស់ នួន ជា ជាមួយសាក្សី TCW-223 មានតាំងពីនៅមុនសន្និសីទទីក្រុងហ្សឺណែវ គឺប្រហែលជា ៦០ឆ្នាំ កន្លងមកហើយ។ ដោយចាប់ពីពេលនោះមក គឺនៅពេលដែលគាត់បានក្លាយជាសមាជិកនៃបក្សកុម្មុយនីស្តឥណ្ឌូចិន និង នួន ជា បានធ្វើការយ៉ាងជិតស្និទ្ធជាមួយ TCW-223 ។ បើតាម នួន ជា សាក្សី TCW-223 មានតួនា

---

[5] ឯកសារ **E-3/1593** [redacted]។

[6] ឯកសារ **E-236/5/1** "សំណើសុំកោះហៅសាក្សី TCW-223 ជាសាក្សីតែមួយគត់ពាក់ព័ន្ធនឹងអត្តចារិតរបស់ នួន ជា" ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣ ។

ទីជានិវេសារបស់គាត់។ បុរសទាំងពីរនេះជួបមុខគ្នាយ៉ាងហោចណាស់ម្តងក្នុងមួយខែដែរ។ ភារកិច្ចដទៃទៀតរបស់សាក្សី TCW-223 គឺថាគាត់អមដំណើរ នួន ជា ទៅព្រំដែនវៀតណាម នៅពេល នួន ជា ត្រូវធ្វើដំណើរបែបនេះ។ ថ្វីត្បិតមានអ្នកនាំសារ ឬកងការពារច្រើននាក់ចូលរួមការធ្វើដំណើរទាំងនេះមែន តែមានតែសាក្សី TCW-223 ទេ ដែលធ្វើដំណើរផ្ទាល់ជាមួយ នួន ជា។ នួនជា និយាយថា "ជីវិតរបស់គាត់ពឹងផ្អែកទាំងស្រុង" លើសាក្សី TCW-223 ។ សាក្សី TCW-223 បានប្រាប់ Ben Kiernan ថានៅទសវត្សរ៍ឆ្នាំ ១៩៦០ គាត់បានអមដំណើរ នួន ជា "គ្រប់កិច្ចប្រជុំរបស់មជ្ឈិមនៅមូលដ្ឋាន"។

ក្រោយរដ្ឋប្រហារឆ្នាំ ១៩៧០ នួន ជា បន្តទំនាក់ទំនងជាមួយសាក្សី TCW-223 ដែលគ្រានោះ សាក្សីរូបនេះជាឥស្សរជនសំខាន់ម្នាក់ក្នុងឋានានុក្រមខ្មែរក្រហម។ កំណត់ហេតុនៃការសម្ភាសន៍របស់គាត់ជាមួយលោក Ben Kiernan បង្ហាញថានៅក្នុងអំឡុងពេលនោះ សាក្សី TCW-223 មានទំនាក់ទំនងស្គាល់គ្នាមិនផ្លូវការជាមួយ នួន ជា: សាក្សី TCW-223 បានពន្យល់ថាគាត់ និងមនុស្សដទៃទៀតក្នុង "ក្រុមរបស់គាត់... បានហៅ នួន ជា ថា "តា ប្រហុក" យើងនិយាយថា "អើ... ខ្ញុំបានជួប តា ប្រហុក" ។ល។ និង ។ល។ ហើយពួកគេយល់ ព្រោះបុរសចំណាស់ម្នាក់នោះ គឺជាមនុស្សដែលហូបប្រហុកច្រើន"[7] ។

នេះគឺជាសំណើលើកទី៤ សុំកោះហៅ សាក្សី TCW-223 ។

---

[7] ឯកសារ **E-236/5/1** "សំណើសុំកោះហៅសាក្សី TCW-223 ជាសាក្សីតែមួយគត់ពាក់ព័ន្ធនឹងអត្តចារិតរបស់ នួន ជា" ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣ នៅកថាខណ្ឌ៣-៤។

៧. នៅថ្ងៃទី១៧ មិថុនា ឆ្នាំ២០១៣ ក្រុមមេធាវីការពារក្តីបានលើកម្តងទៀតនូវសំណើរបស់ខ្លួនសុំកោះហៅសាក្សី TCW-223 សម្រាប់គោលបំណងផ្តល់សក្ខីកម្មទាក់ទងនឹងចេតនារបស់ នួន ជា ពាក់ព័ន្ធនឹងការប្រព្រឹត្តមកលើអតីតទាហាន និងមន្ត្រីរបស់សាធារណរដ្ឋខ្មែរ[8]។ មូលដ្ឋានអង្គហេតុរបស់សំណើនេះ គឺដូចគ្នាទៅនឹងសំណើខែសីហាឆ្នាំ២០១២ ។ សំណើនេះបានស្វែងរកឲ្យពិចារណាឡើងវិញនៃការបដិសេធរបស់អង្គជំនុំជម្រះលើសំណើខែសីហា ឆ្នាំ២០១២ ដោយសារសេចក្តីសម្រេចជាបន្តបន្ទាប់របស់អង្គជំនុំជម្រះបន្ថែមការចោទប្រកាន់នានាទាក់ទងនឹងការសម្លាប់នៅទួលពោធិ៍ជ្រៃ នៅក្នុងវិសាលភាពនៃការជំនុំជម្រះនៅក្នុងករណី០០២/០១។ នេះគឺជាសំណើលើកទី៥ សុំកោះហៅសាក្សី TCW-223 ។

៨. សំណើនិមួយៗ គឺមិនត្រូវបានបដិសេធ ហើយក៏មិនត្រូវបានសម្រេចជាក់លាក់ដោយអង្គជំនុំជម្រះដែរ ។ នៅពេលថ្មីៗបំផុតនេះ គឺនៅថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១៣ មន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះចង្អុលបង្ហាញតាមរយៈសារអេឡិចត្រូនិកថា អង្គជំនុំជម្រះមិនអាចមានការព្រមព្រៀងទាក់ទងនឹងការចូលខ្លួនរបស់សាក្សី TCW-223 ឡើយ[9]។

## II. អំណះអំណាង

៩. សារសំខាន់នៃសក្ខីកម្មរបស់សាក្សី TCW-223 ចំពោះដំណើរការនិតីវិធីនៅករណី០០២ គឺមិនអាចចោទសួរបានឡើយ នៅខែ មេសា ឆ្នាំ ១៩៧៥។ អតីតសហចៅក្រមស៊ើបអង្កេតអន្តរជាតិ Lemonde សារភាពថានៅឆ្នាំ ២០០៩ គាត់បានផ្ញើរទៅសហការីមួយ ‘qu’il nous fallait absolument interroger’ TCW-223[10]។ តាមពិតការជំនុំជម្រះនៅក្នុងករណី ០០២/០១ មានផ្នែកសំខាន់ពីរ: ដំណាក់កាលពីរ ដំបូងនៃការជន្លៀសប្រជាជនដោយបង្ខំ និងការសម្លាប់ទួលពោធិ៍ជ្រៃ ។ សាក្សី TCW-223 គឺអាចជាសាក្សីសំខាន់តែម្នាក់គត់ពាក់ព័ន្ធនឹងផ្នែកទាំងពីរនេះ។

---

[8] ឯកសារ **E-291** “សំណើជាបន្ទាន់សុំកោះហៅសាក្សីសំខាន់ទាក់ទងនឹងទួលពោធិ៍ជ្រៃ” ចុះថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ២០១៣ នៅកថាខណ្ឌ៣១-៣៣, ៣៩(ក)។

[9] សារអេឡិចត្រូនិកពី Susan Lamb ថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១៣ ។

[10] ឯកសារ **E-189/3/1/7.1.3** ‘Un Juge Face Aux Khmer Rouges’, p. 172. ។

១០. ទាក់ទងនឹងការជន្លៀសប្រជាជនដោយបង្ខំ នួន ជា មិនបានបដិសេធថា ទីក្រុងនានានៅកម្ពុជា មិនត្រូវបានជន្លៀសឡើយ ។ ហើយ នួន ជា ក៏មិនបានបដិសេធដែរថា ការជន្លៀសប្រជាជន ត្រូវបានអនុវត្តតាមការបញ្ជារបស់មជ្ឈិមបក្សដែរ ។ តែ នួន ជា បដិសេធថា ការជន្លៀសខុសច្បាប់នៅក្រោមកាលៈទេសៈនានា[11]។ គាត់ក៏បដិសេធឧក្រិដ្ឋកម្មណាមួយដែលអាចត្រូវបានគេប្រព្រឹត្តក្នុងពេលជន្លៀស ដែលធ្វើឡើងស្របតាមផែនការ ឬការបញ្ជាពីមជ្ឈិមបក្ស។ គាត់រក្សាជំហរថា ឋានានុក្រមផ្លូវការរបស់បក្សកុម្មុនីស្តកម្ពុជា មិនឆ្លុះបញ្ចាំងតថភាពជាក់ស្តែងនៃរចនាសម្ព័ន្ធបញ្ជានៅនឹងកន្លែងឡើយ ហើយថាកងទ័ពទាំងអស់ធ្វើសកម្មភាពក្រោមការបញ្ជាដ៏មានប្រសិទ្ធភាពរបស់មេដឹកនាំភូមិភាគ។ ដូច្នេះបញ្ហាស្នូលនៃអង្គហេតុទាក់ទងនឹងការការពាររបស់ នួន ជា ចំពោះការជន្លៀស គឺពាក់ព័ន្ធស្ថានភាពរស់នៅរបស់ប្រជាជននៅទីក្រុងភ្នំពេញ និងទីកន្លែងផ្សេងទៀតនៅក្នុងប្រទេសកម្ពុជានៅមុនខែមេសា ឆ្នាំ១៩៧៥ និងចរិតលក្ខណៈនៃទំនាក់ទំនងបញ្ជា ដែលភ្ជាប់ (ឬមិនភ្ជាប់) នួន ជា ទៅនឹងកងទ័ពនៅសមរភូមិ និងទំនាក់ទំនងរវាងមជ្ឈិមបក្ស និងមន្ត្រីយោធាភូមិភាគ។

១១. សក្ខីកម្មទាក់ទងនឹងរចនាសម្ព័ន្ធយោធា អំឡុងពេលការជន្លៀសប្រជាជនពីទីក្រុងភ្នំពេញ ត្រូវបានផ្តល់ដោយយោធាដែលមានឋានៈទាប ដែលបដិសេធមិនដឹងអំពី "មេដឹកនាំជាន់ខ្ពស់" ព្រឹត្តិការណ៍នានានៅក្រៅរង្វង់នៃការទទួលខុសត្រូវរបស់ពួកគេ[12]។ សាក្សី TCW-223 គឺជា

---

[11] ឯកសារ **E-163/5/11** "ការសន្និដ្ឋានបឋមទាក់ទងនឹងច្បាប់ដែលនៅជាធរមាន"ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៣ នៅកថាខណ្ឌ៦-២៧។

[12] ឯកសារ **E-1/139.1** "ប្រតិចារិតសវនាការ" ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១២ នៅទំព័រ 51:23-52:8 (ទីក្រុងត្រូវបានបែងចែកជាតំបន់) ។ 53:11-18 (សាក្សី គន់ គីម មិនត្រូវបានអនុញ្ញាតឲ្យចេញពីតំបន់តូចដែលគាត់កំពុងការពារនោះទេ) ។ 54:21-55:16 (មេបញ្ជាការរងនៃកងពលរបស់សាក្សីអាចធ្វើដំណើរចៅក្រៅតំបន់បាន) 55:19-56:12 (មិនដឹងអ្វីដែលនៅក្រៅតំបន់ឈរជើងរបស់គាត់) ។ 71:10-25 (ស្រដៀងគ្នា) ។ 73:24-76:2 (ស្រដៀងគ្នា ០។ ។ឯកសារ . **E-1/140.1**, "ប្រតិចារិកសវនាការ" ចុះថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០១២ នៅទំព័រ 88:2-89:1 (សាក្សី ស៊ុម ជា), 91:14-25, 92:13-19 ។ មាស វឿន ជាមន្ត្រីថ្នាក់កណ្តាលដែលនៅក្រោម TCW-223 ទៅទៀតនៅក្នុងពេលរំដោះភ្នំពេញ។ គាត់បានបញ្ជាក់នៅក្នុងសក្ខីកម្មថា គាត់ត្រូវបានបញ្ជាឲ្យដកថយពីភ្នំពេញភ្លាមៗបន្ទាប់ពីចូល និង ឃើញផ្ទាល់ការជម្លៀសប្រជាជនតិចតួចណាស់ ។ មើល ឯកសារ **E-1/129.1** "ប្រតិចារិកសវនាការ" ថ្ងៃទី ០៣ តុលា ឆ្នាំ ២០១២ ទំព័រ 98:9-25។ ឯកសារ **E-1/130.1**"ប្រតិចារិកសវនាការ" ថ្ងៃទី ០៤ តុលា ២០១៣ ទំព័រ 14:4-17:21។ គាត់បានផ្តល់សក្ខីកម្មថា គាត់បានទទួល

មន្ត្រីយោធាជាន់ខ្ពស់បំផុតរបស់ខ្មែរក្រហមដែលនៅរស់ ដែលបានចូលរួមនៅក្នុងការជម្លៀសប្រជាជនទីក្រុងភ្នំពេញ។ ក្នុងសមត្ថភាពនេះ គាត់មកដល់វិមានឯករាជ្យនៅម៉ោង៩ព្រឹក ថ្ងៃទី ១៧ ខែមេសា ឆ្នាំ១៩៧៥[13]។ គាត់បានរៀបរាប់លម្អិតអំពីអន្តរកម្មជាមួយមេដឹកនាំបក្សនៅពេលដំណាលគ្នានឹងការជន្លៀសប្រជាជនពីទីក្រុងភ្នំពេញ[14]។ ពុំមានសាក្សីណាម្នាក់ដែលត្រូវបានកោះហៅឱ្យផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ អាចប្រៀបធៀបនឹងសាក្សី TCW-223 បានទេ។ ដូច្នេះសាក្សី TCW-223 គឺមានលក្ខណៈពិសេសដើម្បីបំភ្លឺចរិតលក្ខណៈនៃការទំនាក់ទំនងផ្ទាល់របស់មជ្ឈឹមបក្សជាមួយចារីនៃបទល្មើសដែលបានចោទប្រកាន់ និងបញ្ជាមកកាន់ពួកគេប្រសិនបើមាន។

១២. ទាក់ទងនឹងផ្នែកទីពីរនៃការជំនុំជម្រះពាក់ព័ន្ធទួលពោធិជ្រៃ មេធាវីការពារក្តីលើកឡើងជំហរសំខាន់ៗពីរ: គឺថាពុំមានគោលនយោបាយសម្លាប់អតីតទាហាន ឬមន្ត្រីរបស់សាធារណរដ្ឋខ្មែរទេ ហើយថាប្រសិនបើមានការសម្លាប់នៅទួលពោធិ៍ជ្រៃ កាលៈទេសៈនៅជុំវិញការសម្លាប់នេះបានចង្អុលបង្ហាញថា វាត្រូវបានបញ្ជាដោយកម្មាភិបាលនៅមូលដ្ឋាន មិនមែនដោយមជ្ឈឹមបក្សទេ ។ ដូច្នេះសាក្សី TCW-223 គឺជាសាក្សីតែម្នាក់គត់ក្នុងចំណោមសាក្សីពីរនាក់ ដែលអាចមានភស្តុតាងដោយផ្ទាល់អំពីចេតនាណារបស់មជ្ឈឹមបក្ស។ សក្ខីកម្មរបស់គាត់បញ្ជាក់លំអិតអំពីសំដីពិតប្រាកដរបស់ នួន ជា នៅកាលបរិច្ឆេទ ពេលវេលា និងទីកន្លែងជាក់លាក់

---

បញ្ជាពីមេបញ្ជាការកងពលដែលគាត់នៅ និង "អ្វីដែលខ្ញុំដឹងគឺត្រឹមតែថ្នាក់ភូមិភាគតែប៉ុណ្ណោះ"។ សូមមើល ឯកសារ **E-1/129.1** "ប្រតិចារិកសវនាការ" ថ្ងៃទី ០៣ តុលា ឆ្នាំ ២០១២ ទំព័រ90:10-14, 91:5-11 សូមមើលដូចគ្នា ទំព័រ93:4-16, 101:4-8 ។ អៀង ផាន់ដែលមានឋានន្តរស័ក្តប្រហាក់ប្រហែលនឹង មាស វឿន ដែរ បានផ្តល់នូវសក្ខីកម្មស្រដៀងគ្នាដែរ។ សូមមើល ឯកសារ. **E-1/193.1**"ប្រតិចារិកសវនាការ" ថ្ងៃទី ២០ ឧសភា ២០១៣ ទំព័រ 13:19-14:17, 16:16-23 ។ គឺដូចគ្នាពិតប្រាកដទៅនឹង ឆោម សែ។ សូមមើល ឯកសារ **E-1/159.1**, "ប្រតិចារិកសវនាការ" ទំព័រ64:25-65:15 ។ ឯកសារ **E-1/177.1**, "ប្រតិចារិកសវនាការ" ទំព័រ. 11:17-24។ អ៊ុង រ៉េន បានផ្តល់សក្ខីកម្មថា គាត់ត្រូវរបួសក្នុងពេលចូលភ្នំពេញ ហើយមិនបានចូលរួមក្នុងការជម្លៀសប្រជាជនទេ។ សូមមើល ឯកសារ **E-1/157.1**"ប្រតិចារិកសវនាការ" ថ្ងៃទី ៩ ខែ មករា ២០១៣ ទំព័រ 42:19-43:3, 46:7-25 ។

[13] ឯកសារ **E-3/1568** កំណត់ត្រាបទសម្ភាសរបស់ Ben Kiernan ជាមួយ នួន ជា និង ហេង សំរិន ថ្ងៃទី ៣ ខែ ធ្នូ ឆ្នាំ ១៩៩១ ទំព័រ ១៨។

[14] សូមមើលកថាខណ្ឌ ៥ ខាងលើ ។

ហើយដូច្នេះ សក្ខីកម្មរបស់គាត់គឺពិតជាអាចជឿជាក់បាន។ ដូច្នេះការបង្ហាញខ្លួនរបស់គាត់នៅតុលាការ គឺជាសារសំខាន់ពាក់ព័ន្ធជាមួយការជំនុំជម្រះផ្នែកទីពីរនៃករណី០០២/០១ ។

១៣. សាក្សី TCW-223 មិនត្រឹមតែជាសាក្សីអង្គហេតុដ៏សំខាន់តែម្នាក់គត់នៅក្នុងករណីនេះទេ គាត់ក៏ជាសាក្សីពាក់ព័ន្ធនឹងអត្តចារិតតែម្នាក់គត់របស់ នួន ជា នៅក្នុងករណី០០២/០១ ដែរ។ មានតែមនុស្សតិចតួចប៉ុណ្ណោះដែលនៅរស់មកដល់ថ្ងៃនេះនៅកម្ពុជាដែលមានទំនាក់ទំនងដ៏យូរ និងជិតស្និទជាមួយ នួន ជា ក្នុងអំឡុងពេលធ្វើបដិវត្តសង្គមនិយម។ ពិតណាស់ពួកគេទាំងនោះមិនបានចូលខ្លួននៅចំពោះតុលាការនេះទេ។ មេធាវីការពារក្តីមិនដឹងករណីណាមួយនៅតុលាការអន្តរជាតិណាមួយ ដែលការចូលខ្លួនរបស់សាក្សីអត្តចារិតតែម្នាក់គត់របស់ជនជាប់ចោទត្រូវបានបដិសេធដោយផ្អែកលើភាពពាក់ព័ន្ធ ។

១៤. អង្គហេតុពិតប្រាកដដែលសំណើនេះពឹងផ្អែកមកលើត្រូវបានអះអាងដោយសាក្សី Stephen Heder ក្នុងអំឡុងពេលផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ។ លោក Heder យល់ស្របថាសាក្សី TCW-223 បានទាក់ទងជាមួយប៉ុល ពត តាំងពីឆ្នាំ ១៩៦២ មកម្ល៉េះ ហើយបន្ទាប់មកបានចូលរួមក្នុងការ "បង្កើត" កងទ័ពបដិវត្តកម្ពុជា។ លោក Heder បានអះអាងថា TCW-223 បានឡើងជាមេបញ្ជាការកងអនុសេនាធំក្នុងកងទ័ពបដិវត្តកម្ពុជា ហើយនៅថ្ងៃខែ មេសា ឆ្នាំ ១៩៧៥ ជាមេបញ្ជាការកងវរសេនាធំ [redacted][15]។ លោក Heder បានបញ្ជាក់ថា ក្នុងលទ្ធភាពនេះ TCW-223 មានតួនាទីសកម្មក្នុងការវាយកាន់កាប់អ្នកលឿង និង ភ្នំពេញ ហើយក្នុងពេលនោះគាត់បានប្រឆាំងរួចទៅហើយទៅនឹងកងទ័ពរបស់មជ្ឈិមបក្ស[16]។

១៥. មេធាវីការពារក្តីកត់សម្គាល់ថា អង្គជំនុំជម្រះបានស្តាប់សាក្សីយ៉ាងហោចណាស់ ៩៦ រូបមកហើយក្នុងសំណុំរឿង ០០២/០១។ សក្ខីកម្ម TCW-223 នឹងកាន់តែបញ្ជាក់ការពិតបន្តទៅទៀតទាក់ទងនឹងបញ្ហាវិវាទពិតប្រាកដនៃអង្គហេតុជាងសាក្សីណាទាំងអស់។

១៦. ដោយសារតែអង្គហេតុទាំងនេះ មេធាវីការពារក្តីស្នើសុំការពិចារណាឡើងវិញនូវសេចក្តីសម្រេចរបស់អង្គជំនុំជម្រះក្នុងការកោះហៅសាក្សី TCW-223 ដោយផ្អែកលើមូលដ្ឋានពីរ។

---

[15] សេចក្តីព្រាងប្រតិចារិក (អង់គ្លេស) ១៦ កក្កដា ២០១៣ ទំព័រ ៩៧:១៥-១០១:១។

[16] សេចក្តីព្រាងប្រតិចារិក (អង់គ្លេស) ១៦ កក្កដា ២០១៣ ទំព័រ ៩៧:១៥-១០១:១។

ទីមួយសេចក្តីសម្រេចរបស់អង្គជំនុំជម្រះក្នុងការមិនកោះហៅសាក្សី TCW-223 បើទោះជាការផ្តល់សក្ខីកម្មរបស់សាក្សីនេះមានសារៈសំខាន់ក្នុងករណីនេះគឺជា "សំអាងហេតុដែលមានវិការៈ"[17]។ ទីពីរសេចក្តីសម្រេចរបស់អង្គជំនុំជម្រះមិនកោះហៅសាក្សី TCW-223 ដោយមិនគិតពីសារធាតុដោះបន្ទុកនៃសក្ខីកម្មនឹង "មិនយុត្តិធម៌"[18]។ មូលដ្ឋាននីមួយៗបង្កើតបានជាមូលដ្ឋានដោយឯករាជ្យមួយសម្រាប់ការពិចារណានៅក្រោមកាលៈទេសៈក្នុងសំណុំរឿងនេះ។

## III. ការទទួលយកសក្ខីកម្មជាលាយលក្ខណ៍អក្សរ

១៧. នៅថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៣ ក្នុងអំឡុងពេលសួរដេញដោល Stephen Heder សហព្រះរាជអាជ្ញាកត់សម្គាល់ថា មេធាវីការពារក្តីបានពឹងផ្អែកលើឯកសារ E3/1568 ជាកំណត់ហេតុជាលាយលក្ខណ៍អក្សររបស់សាក្សី TCW-223 ដែលមេធាវីបានជំទាស់ពីលើកមុន។ សហព្រះរាជអាជ្ញាបានលើកឡើងថា:

> ក្នុងពេលនេះលោកប្រធាន មេធាវីបានយោងទៅលើកំណត់ហេតុនេះ វាហាក់ដូចជាថា មេធាវីកំពុងតែដកការជំទាស់របស់ខ្លួនទៅលើការទទួលយកកំណត់ហេតុដោយពុំមានការសួរដេញដោលសាក្សី។
>
> ដូចនេះសំណើរបស់ខ្ញុំក្នុងពេលនេះមានពីរៈ ទីមួយសុំឲ្យមេធាវីបញ្ជាក់ជំហររបស់ខ្លួន និងប្រសិនបើមិនត្រូវបានបញ្ជាក់ឲ្យបានគ្រប់គ្រាន់។ ទីពីរសម្រាប់ឲ្យអង្គជំនុំជម្រះកត់សម្គាល់សំណើរបស់ខ្ញុំថ្ងៃនេះជាកត្តាមួយដើម្បីពិចារណានៅពេលដែលអង្គជំនុំជម្រះសម្រេចក្នុងការទទួលយកកំណត់ហេតុដោយមិនមានការដេញដោល[19]។

១៨. ក្នុងការឆ្លើយតបនឹងបញ្ហាទីមួយរបស់សហព្រះរាជអាជ្ញា ក្រុមមេធាវីការពារក្តីរបស់លោក នួន ជា សូមអះអាងដោយគ្មានមន្ទិលសង្ស័យថា ខ្លួននៅតែរក្សារាល់ការជំទាស់របស់ខ្លួនទៅ

---

[17] ឯកសារ **C-22/I/68** "សេចក្តីសម្រេចលើបណ្តឹងសុំឲ្យពិចារណាឡើងវិញនូវសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការបញ្ជាក់ជូនអង្គបុរេជំនុំជម្រះដោយផ្ទាល់" ២៨ សីហា ឆ្នាំ២០០៨ ERN 00221475-00221475 កថាខណ្ឌ ២៥ (ទទួលយកការពិចារណារបស់បទដ្ឋានតុលាការជាន់ខ្ពស់ ICTY)។

[18] ដូចខាងលើ។

[19] សេចក្តីព្រាងប្រតិចារិក (អង់គ្លេស) ១៧ កក្កដា ២០១៣ ទំព័រ ៦២:១៣-២២។

លើកំណត់ហេតុ ពាក្យបណ្ដឹង ប្រតិចារិក ដែលស្នើសុំដោយសហព្រះរាជអាជ្ញា និង ដើមបណ្ដឹងរដ្ឋប្បវេណី[20]។

១៩. មេធាវីការពារក្ដីសូមដាក់ជូនថា ជំហរនេះនៅតែច្បាស់ និង យល់ឃើញថា សំណើទីពីររបស់សហព្រះរាជអាជ្ញានៅតែមិនត្រូវបានសម្រេច។ មេធាវីការពារក្ដីសូមលើកឡើងថា ការប្រើឯកសារ E3/1568 មិនមានពាក់ព័ន្ធអ្វីទាល់តែសោះចំពោះការពិចារណារបស់ខ្លួនមកលើការជំទាស់ទៅនឹងការស្នើដាក់ឯកសារនៅចំពោះមុខអង្គជំនុំជម្រះ។ ដូចដែលនៅក្នុងសំណើនេះធ្វើឡើងយ៉ាងច្បាស់ថា មេធាវីនៅតែបន្តសុំឲ្យមានការផ្ដល់សក្ខីកម្មរបស់ TCW-223 ។ ហើយប្រសិនបើគាត់ចូលខ្លួនមកផ្ដល់សក្ខីកម្ម នោះកំណត់ហេតុ E3/1568 នឹងត្រូវបានទទួលយកជាភស្តុតាង។ មេធាវីការពារក្ដីកត់សម្គាល់បន្ថែមទៀតថា បើទោះជាសវនាការកំពុងតែដំណើរការរយៈពេល២០ខែក៏ដោយ ក៏ពុំទាន់មានសេចក្ដីសម្រេចណាមួយលើការជំទាស់របស់មេធាវីការពារក្ដីឡើយ។ សម្រាប់ហេតុផលទាំងពីរនេះ បញ្ហាថាតើ E3/1568 នឹងត្រូវបានទទួលជាភស្តុតាងឬ ក៏អត់នោះ គឺមិនទាន់ដឹងនៅឡើយ។

២០. មេធាវីការពារក្ដីមិនត្រូវបានតម្រូវឲ្យជ្រើសរើសរវាងការជំទាស់ទៅនឹងឯកសារ ដែលខ្លួនគិតថា មិនត្រូវបានទទួលយក និង ការយោងនៅក្នុងអំឡុងពេលសួរដេញដោល ដែលកំពុងតែរង់ចាំសេចក្ដីសម្រេចចុងក្រោយពីអង្គជំនុំជម្រះនោះទេ។ ហើយប្រសិនបើអង្គជំនុំជម្រះសម្រេចថា កោះហៅសាក្សី TCW-223 ឬក៏ទទួលយក E3/1568 ដោយមិនមានការដេញដោល នោះមេធាវីការពារក្ដីប្រើប្រាស់ឱកាសរបស់ខ្លួន ក្នុងការប្រើប្រាស់ភស្តុតាងដាក់បន្ទុកដ៏មានសារសំខាន់នេះ។

២១. ជាចុងបញ្ចប់និងសម្រាប់កំណត់ហេតុ មេធាវីការពារក្ដីកត់សម្គាល់ថា ការជំទាស់របស់ខ្លួនលើ E3/1568 គឺដូចគ្នាទៅនឹងការជំទាស់របស់ខ្លួនទៅនឹងកំណត់ហេតុទាំងអស់ទៀតដែរ គឺជំទាស់

---

[20] ឯកសារ **E-96/8/1** “ការឆ្លើយតបជាបឋមទៅនឹងសំណើបន្ថែមរបស់សហព្រះរាជអាជ្ញាសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនូវកំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី និងប្រតិចារិក” ថ្ងៃទី ០៨ វិច្ឆិកា ឆ្នាំ ២០១២។ ឯកសារ **E-223/2/8** “ការជំទាស់ទៅនឹងសំណើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះនូវ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី និងប្រតិចារិក” ថ្ងៃទី ២៦ ខែមេសា ឆ្នាំ ២០១៣។ ឯកសារ **E-223/2/8/1** “ឧបសម្ព័ន្ធបន្ថែមទាក់ទងនិងការជំទាស់នឹងកំណត់ហេតុស្ដាប់ចម្លើយ និងប្រតិចារិក” ២៩ ខែ មេសា ឆ្នាំ ២០១៣។

នូវការទទួលយកដោយពុំមានការសួរដេញដោលសាក្សី។ ដោយមានការស្នើសុំជាញ៉ើកញាប់របស់មេធាវីការពារក្តីឲ្យកោះហៅសាក្សី TCW-223 ការលើកឡើងរបស់សហព្រះរាជអាជ្ញាថា ការជំទាស់របស់មេធាវីការពារក្តីទៅនឹងការទទួលយកឯកសារ E3/1568 គឺមិនត្រឹមត្រូវទេ។ មេធាវីការពារក្តីគាំទ្រយ៉ាងពេញលេញនូវវត្តមានសាក្សី TCW-223 និងការទទួលយកឯកសារ E3/1568។ ប្រសិនបើអង្គជំនុំជម្រះសម្រេចថា មិនកោះហៅសាក្សី TCW-223 ជាមួយនឹងអនុភាពនៃការសម្រេចមិនទទួលយកឯកសារE3/1568 នោះដូចហេតុផលមានក្នុងសំណើនេះវានឹងរំលោភយ៉ាងធ្ងន់ធ្ងរលើសិទ្ធិទទួលបានការកាត់ក្តីដោយយុត្តិធម៌របស់លោក នួន ជា។

## IV. សេចក្តីសន្និដ្ឋាន និង សំណើ

២២. មេធាវីការពារក្តីសូមស្នើដោយគោរពដល់អង្គជំនុំជម្រះសុំឲ្យកោះហៅសាក្សី TCW-223 ដើម្បីផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះនេះ និងបដិសេធសំណើដោយផ្ទាល់មាត់របស់សហព្រះរាជអាជ្ញានៅថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ២០១៣ ទាក់ទងនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី ពាក្យបណ្តឹង និងប្រតិចារិក។

**សហមេធាវីការពារក្តីលោក នួន ជា**

Victor KOPPE